# ប្រការ ១០ យ៉ាងដែលលោកអ្នកមិនធ្លាប់បានដឹង

១- ធនាគារពិភពលោក ជាអ្នកផ្តល់មូលនិធិពីខាងក្រៅ ដល់ការអប់រំធំជាងគេក្នុងពិភពលោក តាំងពីមូលនិធិសំរាប់ការអប់រំ បាន ចាប់ផ្តើមដំបូងក្នុងឆ្នាំ៩៦៣ ធនាគារពិភពលោក បានផ្តល់ប្រាក់កម្ចី និងឥណទាន ចំនួនជាង ១ ពាន់លានដុល្លាអាមេរិក ហើយបច្ចុប្បន្ន កំពុងផ្តល់ថវិកាដល់គំរោងចំនួន ១៥៨ នៅក្នុង៨៣ ប្រទេស ។ តាមរយៈការធ្វើការយ៉ាងជិតស្និទ្ធ ជាមួយរដ្ឋាភិបាលនានា ភ្នាក់ងារនានា របស់សហប្រជាជាតិអ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាល និងដៃគូឯទៀត១ទាំងឡាយនានា បានជួយបណ្តាប្រទេសកំពុងរីកចំរើន ក្នុងការខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីសំរេចគោលដៅ " ការអប់រំសំរាប់ទាំងអស់គ្នា " ធ្វើអោយកុមារទាំងអស់ទទួលបាននូវការ អប់រំទូទៅថ្នាក់បឋមត្រឹមឆ្នាំ ២០១៥ និងកាត់បន្ថយគំលាតនៃការអប់រំរវាងកុមារា និងកុមារី ត្រឹម ឆ្នាំ២០០៥ ។

ឧទាហរណ៍ ដ៏ល្អមួយនៃការអោយខ្ចីប្រាក់ដោយធនាគារសំរាប់ការអប់រំគឺ "កម្មវិធីអប់រំថ្នាក់បឋមនៅឥណ្ឌា" ដែលគាំទ្រស្រុកទាំងឡាយ ដែលមានអត្រាអក្ខរជនភេទស្រីទាបជាងអត្រាមធ្យមថ្នាក់ជាតិ។ ការផ្តល់មូលនិធិ ដោយធនាគារសំរាប់កម្មវិធីនេះបានកើនឡើងដល់ ១,៣០០ លានដុល្លាអាមេរិកបំរើដល់សិស្សជាង ៦០លាន នាក់ស្រុកចំនួន ២៧១ នៅក្នុងរដ្ឋចំនួន១៨ ក្នុងចំណោមរដ្ឋចំនួន ២៩ នៃប្រទេសឥណ្ឌា។ នៅប្រទេសប្រេស៊ីល អែលសាលវ៉ាឌ័រ និងទ្រីនីដាត-តូបាហ្គោ គំរោងទាំងឡាយរបស់ ធនាគារមានតួនាទីនាំមុខគេ នៅក្នុងសហគមន៍នានាក្នុងការកែលំអគុណភាពនៃការអប់រំ ធ្វើអោយពួកគេអាចវាយតំលៃលើការងាររបស់សាលានិងគ្រូទាំងឡាយនៅ តាមមូលដ្ឋានបាន ។

២- ធនាគារពិភពលោកជាអ្នកផ្តល់មូលនិធិសំរាប់ប្រយុទ្ធនឹងជំងឺអេដស៍ធំជាងគេក្នុងពិភពលោកក្នុងមួយថ្ងៃ១ ប្រជាជនជាង ១៤០០០ ឆ្លង វីរុសហ៊ីវ វី អេត-អាយ-វី (HIV) ហើយពាក់កណ្តាលនៃចំនួននេះមានអាយុពី ១៥ ទៅ ២៤ ឆ្នាំ។ វីរុសហ៊ីវ និងជំងឺអេដស៍ (ហ៊ីវ-អេដស៍) កំពុងច្រានសមិទ្ធផលសង្គម និងសេដ្ឋកិច្ច ដែលបណ្តាប្រទេសកំពុងរីកចំរើន ដណ្តើមបានក្នុងរយៈពេលជាង ៥០ឆ្នាំកន្លងមក អោយត្រលប់ថយក្រោយវិញ ។ ធនាគារពិភពលោក (ជាអ្នករួមឧបត្ថម្ភដល់កម្មវិធីហ៊ីវ-អេដស៍សហប្រជាជាតិ (UNAIDS) ដែលមាន ទិសដៅដឹកនាំចលនាមួយកំពុងរីកសាយនៅទូទាំងពិភពលោក ដើម្បីទប់ទល់នឹងជំងឺឆ្លងនេះ) បានរួមចំណែកផ្តល់ប្រាក់ជាង ១,៧០០ លានដុល្លាអាមេរិក សំរាប់ប្រយុទ្ធនឹងការរីករាលដាលនៃ ហ៊ីវ-អេដស៍ នៅជុំវិញពិភពលោក ហើយបានសន្យាថា នឹងផ្តល់មូលនិធិដល់រាល់ប្រទេស ដែលមានយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពល្អសំរាប់ប្រយុទ្ធនឹងជំងឺនេះ។ ក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល នៃបណ្តាប្រទេសអាព្រិចទាំងឡាយ ធនាគារបានផ្សព្វផ្សាយកម្មវិធីហ៊ីវ-អេដស៍ពហុប្រទេស ដែលក្លាយជាប្រភពផ្តល់អំណោយដ៏សំខាន់ សំរាប់អង្គការសង្គមស៊ីវិល និងសហគមន៍នានា ដែលបង្កើតបានកម្មវិធីអន្តរាគមន៍ទល់ និងហ៊ីវ-អេដស៍ថ្មីប្លែកពីគេក្នុងពិភពលោក ។ ក្នុងឆ្នាំ២០០២នេះ កម្មវិធី ហ៊ីវ-អេដស៍ ពហុប្រទេសបានផ្តល់ថវិកា ១,០០០ លានដុល្លាអាមេរិក ជួយប្រទេសចំនួននៅអាហ្វ្រិក ដើម្បីពង្រីកកម្មវិធីថ្នាក់ជាតិ

សំរាប់បង្ការថែទាំ និង ព្យាបាលជំងឺនេះ។ ធនាគារទើបនឹងយល់ព្រមផ្តល់មូលនិធិ ១៩៥លានដុល្លា អាមេរិកសំរាប់ប្រយុទ្ធនឹងហ៊ីវ-អេដស៍ នៅបណ្តាប្រទេសការ៉ាប៊ិន និងបន្តរជួយគាំទ្រកម្មវិធី ហ៊ីវ-អេដស៍ តទៅទៀតដល់គ្រប់តំបន់។

៣- ធនាគារពិភពលោក ជាអ្នកផ្តល់មូលនិធិពីខាងក្រៅ សំរាប់កម្មវិធីសុខភាពនានាធំជាងគេក្នុងពិភពលោក ការផ្តល់សុខភាព មូលដ្ឋាន និងចំណីអាហារដល់ប្រជាជនក្រីក្រទាំងឡាយ គឺជាអាទិភាពនៃការកាត់បន្ថយភាពក្រីក្រ និងការជំរុញអោយមានកំណើន សេដ្ឋកិច្ច ។ ថ្វីបើប្រទេសជាច្រើនដណ្តើមបានសមិទ្ធផលសំខាន់ៗ នៅក្នុងរយៈពេលម្ភៃសាមសិបឆ្នាំកន្លងទៅនេះក្តី គេនៅឃើញមាន ការទាមទារធំៗផ្សេងទៀត ។ ក្នុងចំណោមកុមារ១១លាននាក់ដែលបានស្លាប់ក្នុងមួយឆ្នាំៗ នៅក្នុងបណ្តាប្រទេសកំពុងរីកចំរើន មានកុមារ៧០ភាគរយ ស្លាប់ដោយសារជំងឺដែលអាចព្យាបាលជា រឺអាចចៀសវាងបាន (ដូចជាជំងឺរលាកសួតរាគ គ្រុនចាញ់ កញ្ជ្រឹល និងហ៊ីវ-អេដស៍) និងដោយសារចំណីអាហារមិនគ្រប់គ្រាន់ ។ ធនាគារបានផ្តល់ជាមធ្យម ១,០០០ លានដុល្លាអាមេរិកក្នុងមួយឆ្នាំជាការអោយខ្ចីថ្មីៗ សំរាប់គំរោងនានានៃវិស័យសុខភាព ចំណីអាហារ និង ប្រជាជននៅក្នុងបណ្តាប្រទេសកំពុងរីកចំរើន ។ មូលនិធិ នានារបស់ធនាគារបានជួយក្នុងការប្រយុទ្ធ នឹងជំងឺគ្រុនចាញ់ នៅក្នុងប្រទេសចំនួន ៤៦ និងជំងឺរបេង នៅក្នុងប្រទេសចំនួន ៣០ ។ នៅក្នុងប្រទេសចិន ធនាគារបានជួយផ្តល់អំបិលមានជាតិអ៊ីយ៉ូត សំរាប់តំរូវការក្នុងគ្រួសារជាង ៩០ភាគរយ ធានាអោយគ្រួសារ ជាច្រើនលាន ទទួលបានប្រយោជន៍ ជាការថយចុះនៃករណីរលូតកូន និងកូនប្រសូតមក ស្លាប់រូបរាងខុសប្រក្រតី និងភាពយឺតយ៉ាវ ខាងគំនិតបញ្ញាដែលបណ្តាលមកពីខ្វះជាតិអ៊ីយ៉ូត ។ ធនាគារពិភពលោកក៏បានជួយមាតា ជាច្រើននៅប្រទេស សេណេកាល់ ក្នុងការ ការពារ និងព្យាបាលជំងឺខ្វះចំណីអាហារ ដល់កូនៗរបស់គេ ហើយក៏កំពុងជួយគាំទ្របញ្ចូលការការពារ និងការព្យាបាលជំងឺកុមារនៅ ប្រទេសប្រេស៊ីល

៤- ធនាគារពិភពលោកគាំទ្រជាខ្លាំង ដល់ការកាត់បន្ថយបំណុលក្នុងឆ្នាំ១៩៩៦ ធនាគារពិភពលោក និង មូលនិធិរូបិយវត្ថុពិភព លោកបានបំផុសការផ្តួចផ្តើមគំនិតមួយ សំរាប់បណ្តាប្រទេសក្រីក្រជំពាក់បំណុលគេច្រើន ។ នេះជាការឆ្លើយតបថ្នាក់អន្តរជាតិលើក ទីមួយដែលផ្តល់ការកាត់បន្ថយបំណុលគួរអោយចាប់អារម្មណ៍ ទៅអោយបណ្តាប្រទេសក្រីក្រជាងគេ និងបណ្តាប្រទេសជំពាក់បំណុល គេច្រើនៗបំផុត ។ សព្វថ្ងៃប្រទេសចំនួន ២៦ បានទទួលការកាត់បន្ថយបំណុលដែលគិតជាប្រាក់ស្មើនឹង ៤០ពាន់លានដុល្លាអាមេរិក ។ បូកជាមួយនឹងទំរង់ផ្សេងៗទៀត នៃការកាត់បន្ថយបំណុល ការផ្តួចផ្តើមគំនិតសំរាប់បណ្តាប្រទេសក្រីក្រជំពាក់បំណុលគេច្រើន នឹងកាត់ បំណុលខាងក្រៅរបស់ប្រទេសទាំងនោះចោល ប្រមាណពីរភាគបី គឺនឹងបញ្ចុះទំហំបំណុលអោយនៅទាបជាងកំរិតមធ្យម សំរាប់ប្រទេស កំពុងរីកចំរើនទាំងអស់រួមគ្នា ។ ក្នុងផ្នែកមួយរបស់ការ ផ្តួចផ្តើមគំនិតសំរាប់បណ្តាប្រទេសក្រីក្រនេះ គេបានប្តូរទិសអាទិភាពថវិកា របស់ពួកគេឆ្ពោះទៅរកចំណុចគន្លឹះ នៃការអភិវឌ្ឍន៍សង្គម និង មនុស្ស ។ ជាឧទាហរណ៍ប្រទេសវ៉ាន់ដាបានកំណត់ទិសឆ្ពោះទៅ បង្កើនការចុះឈ្មោះចូលរៀនសាលាបឋមសិក្សា និងការជួលគ្រូទាំងឡាយ ។ ប្រទេសហុង

ឱ្យរ៉ាស់កំពុងលើកផែនការផ្តល់កញ្ចប់ សុខភាពមូលដ្ឋាន ដែលក្នុងនោះ មានការថែទាំសុខភាពបឋមព្រមទាំងសុខភាពមាតា និងទារក ដល់បណ្តាជនយ៉ាងតិចមួយសែននាក់ នៅក្នុងសហគមន៍ក្រីក្រទាំងឡាយ ។ នៅក្នុងប្រទេសកាមេរូនគេបានប្រើប្រាស់ធនធានទាំងនោះ សំរាប់ពង្រឹងការប្រយុទ្ធនឹង ហ៊ីវ-អេដស៍ ក្នុងនេះគេបានពង្រីកការអប់រំផ្សព្វផ្សាយអំពីការប្រើស្រោមអនាម័យទៅក្នុងចំណោមប្រជាជន ដែលមានភាព ប្រថុយប្រថាន ខ្ពស់ ។

៥- ធនាគារពិភពលោក ជាអ្នកផ្តល់មូលនិធិអន្តរជាតិដ៏ធំជាងគេមួយ ទៅអោយគំរោងជីវចំរុះនានា តាំងពីឆ្នាំ ១៩៨៨ មកធនាគារ បាន ក្លាយជាអ្នកផ្តល់មូលនិធិអន្តរជាតិដ៏ធំជាងគេមួយ ទៅអោយគំរោងជីវចំរុះនានា ។ ការថែរក្សាជីវចំរុះជាអាទិភាពចំបងមួយរបស់ ធនាគារពិភពលោក ព្រោះថាថ្វីបើការបាត់បង់ជីវចំរុះជាកង្វល់សកលមួយក្តីការខាតបង់ធំជាងគេ បានប៉ះពាល់ដល់ប្រជាជន នៅក្នុង បណ្តាប្រទេសកំពុងរីកចំរើន ដែលពឹងផ្អែកលើជីវចំរុះនេះ ដើម្បីដោះស្រាយបញ្ហាចំណីអាហារ ជំរក ថ្នាំព្យាបាលរោគ ចំណូលការងារ និងអត្តសញ្ញាណវប្បធម៌ ។ ក្នុងឆ្នាំកន្លងមកនេះ ធនាគារបានចូលរួមជាមួយ"ការថែរក្សាអន្តរជាតិ" និង"គ្រឿងបរិក្ខារសំរាប់បរិស្ថាន ពិភពលោក" ក្នុងការបង្កើតមូលនិធិមួយសំរាប់ចូលរួមការពារតំបន់ជីវចំរុះកំពុងរងគ្រោះ ទាំងឡាយ នៅក្នុងបណ្តាប្រទេសកំពុង រីកចំរើន — ក្នុងតំបន់រងការគំរាមកំហែងទាំងនោះ មានសត្វលោកជំពូកផ្សេងៗ ប្រមាណ៦០% នៃសត្វលោកចំរុះទាំងមូលហើយស្ថិត នៅលើផ្ទៃដីតែ ១,៤% នៃផ្ទៃផែនដីយើងប៉ុណ្ណោះ ។ កង្វល់ចំពោះបរិស្ថានជាផ្នែកសំខាន់ជាងគេនៃគោលដៅកាត់បន្ថយភាពក្រីក្រ របស់ធនាគារ ។ ជាបន្ថែមទៅលើគោលនយោបាយនានាទាក់ទងនឹងការប៉ាន់ប្រមាណ និងការរក្សាការពារបរិស្ថាន យុទ្ធសាស្ត្របរិស្ថាន ថ្មីកំពុងផ្តោតទៅលើបំរែបំរួលអាកាសធាតុ ព្រៃឈើ ធនធានទឹក និងជីវចំរុះ។ បច្ចុប្បន្នគំរោងនានារបស់ធានាគារដែលមានកម្មវត្ថុ ទាក់ទងនឹងបរិស្ថានសុទ្ធមានទំហំ ១៤ពាន់លានដុល្លា អាមេរិក។

៦- ធនាគារពិភពលោក ធ្វើការក្នុងភាពជាដៃគូជាងពេលណាៗទាំងអស់ ក្នុងរយៈពេលប្រាំមួយឆ្នាំកន្លងមកនេះ ធនាគារពិភពលោកបាន ចូលរួមជាមួយដៃគូជាច្រើនក្នុងការប្រយុទ្ធ នឹងភាពក្រីក្រ នៅក្នុងពិភពលោក : រួមជាមួយ " មូលនិធិសត្វព្រៃពិភពលោក" ដើម្បី ការពារព្រៃឈើ និងរួមជាមួយផ្នែកសាធារណៈ និងឯកជននានាង្កើត " មូលនិធិគំរូដើមនៃកាបូន" ដើម្បីជួយបន្ថយផលវិបាកនៃការ ឡើងកំដៅក្នុងពិភពលោក ។ ធនាគារបានចូលរួមជាដៃគូជាមួយអង្គការស្បៀងអាហារនិងកសិកម្ម (FAO) របស់អង្គការសហប្រជាជាតិ និងជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដើម្បីឧបត្ថម្ភ "ក្រុមទីប្រឹក្សាលើការសិក្សាស្រាវជ្រាវកសិកម្មអន្តរជាតិ " ដ៏ល្បី ចូលរួមជាមួយ " មូលនិធិរបស់បងប្អូនរ៉ុកកឺហ្វែលែ " លើកម្មវិធីថាមពលព្រះអាទិត្យ និង ចូលរួមជាមួយអ្នកផ្តល់ជំនួយ និងស្ថាប័ន ផ្តល់មូលនិធិពហុភាគីនានា តាមរយៈក្រុមទីប្រឹក្សា ដើម្បីជួយអ្នកក្រីក្រជាងគេ " (CGAP) ដើម្បីលើកកំពស់លទ្ធភាពរបស់ស្ថាប័ន មីក្រូហិរញ្ញវត្ថុនានា ក្នុងការផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជនក្រីក្រជាងគេ ។ ភាពជាដៃគូមួយដើម្បីបំបាត់ជំងឺខ្វាក់ផ្នែកដែលបង្ក ដោយមេរោគនៅ ក្នុងទឹកទន្លេបានទទួលជោគជ័យក្នុងការការពារច្រើនជាង

៦សែនករណី ហើយក្នុងមួយឆ្នាំៗ បានព្យាបាលអ្នកជំងឺនេះ ប្រមាណ ២២ លាននាក់ និង បានបើកផ្ទៃដីធ្វើកសិកម្មប្រមាណ ២៥លានហិកតា ។

៧- ធនាគារពិភពលោក ជាអ្នកនាំមុខគេក្នុងការប្រយុទ្ធនឹងអំពើពុករលួយ នៅទូទាំងពិភពលោកអំពើពុករលួយ ជាឧបសគ្គចំពោះការ អភិវឌ្ឍន៍ វាបន្ថែមបន្ទុកទៅលើប្រជាជនក្រីក្រដោយបង្វែរធនធានទាំងឡាយពីអ្នកដែលកំពុងត្រូវការខ្លាំងជាងគេ ។ តាំងពីឆ្នាំ១៩៩៦ មកធនាគារបានបង្កើត និងអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយ និង ការផ្តើមគំនិតក្នុងការងារគ្រប់គ្រងចំនួនជាង ៦០០ នៅក្នុង ប្រទេសនានាជាអតិថិជនប្រមាណជិត១០០ ។ ការផ្តើមគំនិតទាំងឡាយមានចាប់ពីការហ្វឹកហ្វឺនចៅក្រម រហូតដល់ការរៀបចំសិក្ខា សាលា និងការបង្រៀនរបៀបរាយការណ៍អំពីការអង្កេតដល់អ្នកសារព័ត៌មានទាំងឡាយ ។ សព្វថ្ងៃស្ទើរតែមួយភាគបួននៃចំនួន គំរោងថ្មីៗ បានបញ្ចូលធាតុស្តីអំពីចំណាយសាធារណៈ និងកំណែទំរង់ហិរញ្ញកិច្ច ។ សំខាន់ជាងនេះទៅទៀតការចូលរួមរបស់ធនាគារ ក្នុងការលុបបំបាត់អំពើពុករលួយ បានជួយបំផុសប្រតិកម្មទៅ នឹងបញ្ហានេះនៅទូទាំងពិភពលោក ។ ធនាគារពិភពលោកកំពុងតែធ្វើការបញ្ចូលនូវវិធានការអភិបាលកិច្ចនិងការប្រឆាំងទៅនឹងអំពើពុករលួយទៅក្នុងផែនការនិងការងារប្រតិបត្តិការ ។ ធនាគារក៏បាន ចូលរួមផងដែរ ក្នុងការធានាអោយគំរោងនានាដែលទទួលមូលនិធិពីខ្លួនគ្មានអំពើពុករលួយ ។ ជាងបួនឆ្នាំកន្លងទៅនេះ ធនាគារបាន បង្កើតបែបបទលទ្ធកម្មយ៉ាងលំអិត និងសេចក្តីណែនាំស្តីពីការប្រយុទ្ធ នឹងអំពើពុករលួយនានា ព្រមទាំងបានតំលើងទូរស័ព្ទផ្ទាល់មួយ ខ្សែសំរាប់ទទួលបណ្តឹងនានាទាក់ទងនឹងអំពើពុករលួយ ។ មកដល់ត្រឹមខែកក្កដា ២០០២ ធនាគារបានប្រកាសថា ក្រុមហ៊ុនចំនួន៧៧ និងបុគ្គលមួយចំនួន លែងមានសិទ្ធិទទួលការងារតាមកិច្ចសន្យាពីធនាគារទៀតហើយ ។

៨- សង្គមស៊ីវិលមានតួនាទីធំជាងពេលណាៗទាំងអស់ នៅក្នុងការងាររបស់ធនាគារពិភពលោកគំរោងអភិវឌ្ឍន៍នានាប្រមាណច្រើនជាង ២ ភាគ ៣ ដែលធនាគារបានយល់ព្រម ក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុមុននេះ ទាក់ទងនឹងការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល ហើយ យុទ្ធសាស្ត្រថ្នាក់ប្រទេសទាំងឡាយរបស់ធនាគារ បានទទួលផលប្រយោជន៍ពីការផ្តល់យោបល់របស់អង្គការក្រៅរដ្ឋាភិបាលនានា ។ បច្ចុប្បន្នយើងមានបុគ្គលិកធ្វើការនៅក្នុងការិយាល័យនានារបស់ធនាគារចំនួន៧០នៅទូទាំងពិភពលោក ដែលទាក់ទងការងារជាមួយ សង្គមស៊ីវិល ។ នៅអាស៊ីខាងត្បូង ធនាគារកំពុងពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល លើយុទ្ធសាស្ត្រដែនឌុំរ នៅអឺរ៉ុបខាងកើត លើជំនួយក្រោយទំនាស់ និងអភិបាលកិច្ច នៅអាមេរិកឡាទីន លើការផ្តល់អំណាច និងឥទ្ធិពលរបស់កំណែទំរង់ទៅលើសង្គម ។ ឧទាហរណ៍ដ៏ល្អនៃការរួមចំណែករបស់សង្គមស៊ីវិល នៅក្នុងគំរោងទាំងឡាយរបស់ធនាគារ គឺនៅទីម័រខាងកើតនៅទីនោះគំរោងនៃការផ្តល់ អំណាចដល់សហគមន៍ និងការគ្រប់គ្រងមូលដ្ឋានបានគាំទ្រក្រុមប្រឹក្សា ភូមិដែលជ្រើសរើសបានមកដោយលក្ខណៈប្រជាធិបតេយ្យ និងមានចំនួនសមាជិកជាយុវវ័យ ស្ត្រីនិងព្រះវិហារ និងក្រុមកសិករ ក្នុងការ

ជួសជុលផ្លូវថ្នល់នានា និងការផ្គត់ផ្គង់ទឹក ការចាប់ផ្តើម សកម្មភាពសេដ្ឋកិច្ចនានាឡើងវិញនិងការផ្តល់ជំនួយផ្ទាល់ដល់អ្នកដែលត្រូវការវាជាងគេ ។

៩- ធនាគារពិភពលោកជួយប្រទេសទាំងឡាយ ដែលទើបឆ្លងផុតទំនាស់បច្ចុប្បន្ន ធនាគារកំពុងធ្វើការនៅក្នុងប្រទេសដែលរងគ្រោះ ដោយសារទំនាស់ចំនួន ៤០ ជួយគាំទ្រការខំប្រឹងប្រែងថ្នាក់អន្តរជាតិទាំងឡាយដើម្បីបំបែករង្វង់ទំនាស់នានា និងជួយជ្រោមជ្រែងប្រជា ជនរងគ្រោះ ដោយសារសង្គ្រាមទាំងឡាយអោយចាប់ផ្តើមការងារអភិវឌ្ឍន៏ក្នុងសន្តិភាព ។ ការងាររបស់ធនាគារមានទិសដៅដោះស្រាយ សេចក្តីត្រូវការមួយចំនួន ដូចជាការចាប់ផ្តើមជំរុញសេដ្ឋកិច្ចអោយស្ទុះទៅមុខ ការវិនិយោគនៅក្នុងតំបន់រងឥទ្ធិពលសង្គ្រាមនានា និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតដោយសារសង្គ្រាម ក៏ដូចជាកម្មវិធីនានាសំរាប់អតីតយុទ្ធជន និងក្រុមអ្នកទន់ខ្សោយ ទាំងឡាយដូចជាស្ត្រីមេម៉ាយ និងកុមារ ។ ធនាគារដ៏បានផ្តល់មូលនិធិផងដែរ ដល់កម្មវិធីនានាដូចជា ការកាត់បន្ថយអាវុធ ការកាត់រំសាយកងទ័ព និងការធ្វើសមាហរណកម្មទាហានរំសាយនោះ ក៏ដូចជាដោះស្រាយ និងសិក្សាបញ្ហាមីន និងការផ្តួចផ្តើមនូវចំណេះដឹងនានា ។ ឧទាហរណ៏ស្តីអំពីគំរោងផ្សេង១ ថ្មី១ទាំងឡាយក្នុងវិស័យនេះ ដែលធនាគារបានជួយឧបត្ថម្ភរួមមានៈ ការស្តារហេដ្ឋា រចនាសម្ព័ន្ធ និងការខិតខំប្រឹងប្រែងផ្តល់អំណាចទៅឱ្យសហគមន៏នៅប្រទេសអាហ្គានីស្ថាន ការអប់រំឡើងវិញនូវលទ្ធភាពក្មេងតាម ចិញ្ចើមថ្នល់ នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ សកម្មភាពអភិវឌ្ឍន៏មូលដ្ឋាននៅប្រទេសស៊ើបៀរខាងត្បូង ការបណ្តុះបណ្តាល មន្ត្រីរដ្ឋាភិបាលនៅទីម៉រខាងកើត និង ការធ្វើកម្មវិធីជំរឿនប្រជាជន និងការចូលរួមនៅក្នុងប្រទេសហៃទី ។

១០- ធនាគារពិភពលោកកំពុងស្តាប់សំលេងទាំងឡាយរបស់បណ្តាជនក្រីក្រ ការសន្ទនាជាមួយប្រជាជនក្រីក្រប្រមាណ ៦០,០០០នាក់ នៅក្នុងប្រទេសចំនួន ៦០ ក៏ដូចជាការងារប្រចាំថ្ងៃ របស់យើង បានបង្រៀនយើងថាភាពក្រីក្រគឺជាអ្វីដែលលើសពីចំណូលមិនគ្រប់គ្រាន់ និងការអភិវឌ្ឍន៏មនុស្សនៅទាបទៅទៀត ។ វាទាក់ទងផងដែរនឹងកង្វះសំលេង កង្វះអ្នកតំណាងរបស់ពួកគេ ។ វាទាក់ទងនឹងភាព ទន់ខ្សោយចំពោះមុខ ការរំលោភបំពាន និងអំពើពុករលួយ ។ វាទាក់ទងនឹងកង្វះសេរីភាពមូលដ្ឋានសំរាប់សកម្មភាពការជ្រើសរើស និងការមានឱកាស ។ យើងជឿថាគេមិនត្រូវចាត់ទុក ប្រជាជនដែលរស់ក្នុងភាពក្រីក្រជាដើមហេតុនៃបញ្ហាទេតែគេគួរចាត់ទុកពួកគាត់ ជាធនធានប្រកបដោយផលិតភាពខ្ពស់ ដែលនឹងចូលរួមចំណែកច្រើនជាងនរណា១ទាំងអស់ ក្នុងការលុបបំបាត់ភាពក្រីក្រ ។ របៀបដោះស្រាយនៃការផ្តល់អំណាច ក្នុងការកាត់បន្ថយភាពក្រីក្រ ដោយយកប្រជាជនអ្នកក្រីក្រដាក់ជាមណ្ឌលកណ្តាលនៃការអភិវឌ្ឍន៏ និង ការបង្កើតលក្ខ័ណ្ឌនានា ដែលជួយឱ្យប្រជាជនក្រីក្រទាំងប្រុស ទាំងស្រីបានទទួលការគ្រប់គ្រងនូវជីវិតរស់នៅរបស់ពួកគេ តាមរយៈការ ទទួលបានពត៌មាន ការបញ្ចូលគំនិត និងការចូលរួមការទទួលខុសត្រូវនិងសមត្ថភាពការរៀបចំអង្គការនៅតាមមូលដ្ឋាន ។ សព្វថ្ងៃ ធនាគារបានចូលរួមចំណែកជាង ២២០០លានដុល្លាអាមេរិក ក្នុងគំរោងអភិវឌ្ឍន៏ថ្នាក់សហគមន៏នានា ។ នៅប្រទេសឥណ្ឌូនេស៊ី ភូមិចំនួន ជាង ១៥០០០ និងក្រុម

សហគមន៍ជាច្រើន កំពុងកសាងសំណើផ្ទាល់របស់ពួកគេ ដើម្បីទទួលបានមូលនិធិថ្នាក់មូលដ្ឋាន។ ឯនៅប្រទេសបេណាំងវិញ ស្ត្រីជាច្រើនកំពុងរួមគ្នាធ្វើការ ដើម្បីការពារព្រៃឈើ និងប្រែក្លាយជាប្រភពចំណូលជាជាងចាត់ទុកវាប្រភពនៃធាតុឆេះ។